កម្មវិធីបង្ហាញ ហើយនិទានប្រាប់

សន្និសីទទូទៅគឺនៅខែនេះហើយ ! នេះជាអ្វីដែលកុមារមួយចំនួនបានរីករាយអំពីសន្និសីទ ។

ខ្ញុំចូលចិត្តស្តាប់រឿងនានា និងក្រុមចម្រៀងច្រៀង ។ ខ្ញុំក៏ចូលចិត្តស្តាប់រឿងប្រៀបប្រដូចដែលពួកលោកថ្លែងផងដែរ ។

យ៉ូ អេច អាយុ ៨ ឆ្នាំ ទីក្រុងតៅយួន ប្រទេសតៃវ៉ាន់

ខ្ញុំចូលចិត្តស្តាប់ព្យាការី ដោយសារព្រះអម្ចាស់មានបន្ទូលតាមរយៈលោក ។

អ៊ែនឌ្រេ សឺ អាយុ ១២ ឆ្នាំ ទីក្រុង ហ៊ីលេ ឌេល តៅកា ប្រទេសកូឡុំប៊ី ។

ខ្ញុំចូលចិត្តមើលសន្និសីទ ដោយសារខ្ញុំចូលចិត្តរៀនពីព្យាការី ហើយខ្ញុំចូលចិត្តចំណាយពេលនោះជាមួយគ្រួសារខ្ញុំ ។

ដាវីឌ ដេ អាយុ ៩ ឆ្នាំ ទីក្រុងសូឡូឡា ប្រទេសហ្គាតេម៉ាឡា

អាបិល សឺ និង ធីណា អេស អាយុ ១០ និង ៩ ឆ្នាំ ទីក្រុង ចង ខោនធី ប្រទេសលីបេរីយ៉ា គឺជាបងប្អូននឹងគ្នា ។ អាបិលចូលចិត្តសន្និសីទ « ដោយសារនោះជាពេលដែលយើងគាំទ្រព្យាការីយើងជាប្រធានសាសនាចក្ររៀងរាល់ឆ្នាំ » ។ ធីណា « ចូលចិត្តសន្និសីទ ពេលព្យាការីថ្លែងអំពីព្រះវិហារបរិសុទ្ធ » ។

អាណា ប៊ី អាយុ ១០ ឆ្នាំ ទីក្រុង ម៉ាហារ៉ាស្ត្រា ប្រទេសឥណ្ឌា បានមើលសន្និសីទជាមួយម្តាយរបស់នាង ។ នាងបានយកសៀវភៅកំណត់ចំណាំ និងប៊ិចទៅជាមួយនៅពេលសន្និសីទម្តងៗ ដើម្បីកត់ទីបន្ទាល់ និងសារលិខិតដែលនាងស្តាប់ឮ ។

ដាវីឌ និង ជូលៀណា អ៊ីម អាយុ ៤ និង ៦ ឆ្នាំ ទីក្រុង ហូឡ្យ៉ាន ខាងត្បូង ប្រទេសហ្ស្លង់ បានដាក់អាហារសម្រន់ ១៥ ចាន ហើយដាក់រូបថតរបស់សាវកម្នាក់ៗ ឬសមាជិកនៃគណៈប្រធានទីមួយនៅលើចានទាំងនោះ ។ ពេលបងប្អូនប្រុសម្នាក់និយាយ ពួកគេបរិភោគអាហារដែលមាននៅក្នុងចាននោះ !

ស៊ីនធ្លាក់ចាស្ស៊ីយ៉ាកី GETTY IMAGES